អន្តរឃ្មី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ សោតាបត្តិផលប្រសើរជាងអំណាចនៅលើផែនដី និងសេចក្តីសុខក្នុងឋានសួគ៌

www.hoksavann,com

ថ្ងៃទី៥ វិច្ឆិកា ២០១០



ពាក្យថា សោតាបត្តិផលប្រសើរជាងអំណាចនៅលើផែនដី និងសេចក្តីសុខក្នុងឋានសួគ៌ ជាពាក្យបំព្រួញពីពុទ្ធភាសិតថា បឋព្យា ឯកនជ្ជេន សគ្គស្ស គមនេនវា សព្វលោកាធិបច្ចេន សោតាបត្តិផលំ វរំ ប្រែថា ៖ សោតាបត្តិផលប្រសើរជាងឯករាជ្យលើផែនដី ជាងទៅកាន់ឋានសួគ៌ និងប្រសើរជាងអធិបតេយ្យនៅក្នុងលោកទាំងមូល ។

ហេតុដែលនាំឲ្យសំដែងគាថានេះឡើង ដោយមានរឿងជាសង្ខេបថា បុត្តសេដ្ឋីម្នាក់ឈ្មោះកាលៈ បានត្រូវឪពុកជួលឲ្យទៅរក្សាឧបោសថសីល ដោយឲ្យរង្វាន់១០០កហាបណៈ ។ យុវ-ជនកាលៈបានទៅវត្ត តែពុំបានរក្សាឧបោសថសីលទេ ទៅពួនសម្ងំដេកនៅទីស្ងាត់មួយ ។ លុះព្រលឹមឡើងប្រញាប់ទៅផ្ទះវិញ ដើម្បីទារយកថ្លៃឈ្នួល១០០កហាបណៈពីឪពុក ។ ថ្ងៃក្រោយទៀត អនាថបិណ្ឌិកសេដ្ឋីជាឪពុកបានជួលកាលៈជាកូន ឲ្យទៅស្តាប់ធម៌ម្តង ឲ្យចាំបានតែមួយបទ នឹងផ្តល់ឲ្យប្រាក់ចំនួន១០០០កហាបណៈ ។ ពេលកាលៈកំពុងស្តាប់ធម៌ ព្រះពុទ្ធបានជ្រាប ព្រះអង្គធ្វើមិនឲ្យកាលៈចាំធម៌ណាមួយសោះ ។ ដោយចង់បានប្រាក់ យុវជនកាលៈខំព្យាយាមស្តាប់ដោយយកចិត្តទុកដាក់ ដោយមានឧបនិស្ស័យពីមុនមកផង យុវជននោះក៏បានសំរេចសោតាបត្តិផលក្នុងពេលនោះទៅ ។ លុះព្រលឹមឡើង ព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន បាននិមន្តទៅផ្ទះសេដ្ឋីដើម្បីទទួលភត្ត ដោយយុវជនកាលៈទៅជាមួយផង ។ បន្ទាប់ពីភត្តកិច្ចចប់ សេដ្ឋីបានលើកប្រាក់១០០០កហាបណៈប្រគល់ទៅឲ្យកូនរបស់ខ្លួន តាមការសន្យាឲ្យទៅស្តាប់ធម៌ ។ យុវជនជាកូនមានការអៀនខ្មាស់ ដើរគេចចេញមិនទទួលយកឡើយ ។ សេដ្ឋីបានក្រាបទូលព្រះពុទ្ធជាម្ចាស់ អំពីរឿងរ៉ាវដែលខ្លួនបានជួលកូនឲ្យទៅស្តាប់ធម៌ ដើម្បីលះបង់នូវមិច្ឆាទិដ្ឋិ ដោយឲ្យថ្លៃឈ្នួល តែពេលនេះហាក់ដូចជាមានអាការៈប្លែក មិនទទួលយកប្រាក់នោះឡើយ ។ ព្រះពុទ្ធមានព្រះពុទ្ធដីកាថា កូនរបស់អ្នកបានសំរេចសោតាបត្តិផលហើយ ទើបព្រះអង្គសំដែងគាថាដូចពោលមកខាងដើមថា សោតា-បត្តិផល ប្រសើរជាងឯករាជ្យនៅលើផែនដី ជាងទៅកាន់ឋានសួគ៌ និងប្រសើរជាងអធិបតេយ្យនៅក្នុងលោកទាំងមូលនេះឯង ។

អ្នកដែលបានសំរេចសោតាបត្តិផលឈ្មោះថា សោតាបន្នបុគ្គល ជាអរិយបុគ្គលថ្នាក់ទី១ ក្នុងបណ្តាអរិយបុគ្គលទាំង៤ពួក ។ ថ្នាក់សោតាលះបង់បានធម៌៣យ៉ាងដោយដាច់ខាត ក្នុងបណ្តាសំយោជនកិលេស១០យ៉ាង ។ ធម៌៣យ៉ាងនោះគឺ សក្កាយទិដ្ឋិ គំនិតយល់ថាជាកាយរបស់ខ្លួន គំនិតយល់ខុសនេះ ថ្នាក់សោតាលះបង់បាន ដោយប្រាជ្ញាជាលោកុត្តរៈកើតឡើងឃើញច្បា-ស់ថា រូបកាយដែលជាខន្ធប្រាំនេះ មានសភាពពុំទៀង ជាទុក្ខ និងជាអនត្តា ពុំមែនជាតួខ្លួនឡើយ ។ វិចិកិច្ឆា សេចក្តីសង្ស័យក្នុងខន្ធ៥ ថ្នាក់សោតាលោកលះបង់បាន គឺប្រាជ្ញាថ្នាក់វិបស្សនាបានកើតឡើងឃើញថា ខន្ធ៥ជាទុក្ខគ្រប់កាលទាំងបី ឲ្យតែកើតឡើងនៃខន្ធ៥ គឺជាទុក្ខ ។ សីលព្វតបរាមាសៈ ប្រែថា ការស្ទាបអង្អែលនូវសីលនិងវត ។ បរាមាសៈ ការស្ទាបអង្អែលបានន័យថា ការប្រកាន់, វតៈការប្រព្រឹត្ត, សីលៈជាប្រក្រតី រួមសេចក្តីមក សីលព្វតបរាមាសៈ ប្រែថា ការប្រកាន់ការប្រព្រឹត្តជាប្រក្រតី ។ បានសេចក្តីថា កាលសម័យដើម សាសនាហិណ្ឌូបានប្រព្រឹត្តតាមអាការៈសត្វឆ្កែនិងសត្វគោ ហៅថាវតឆ្កែនិងវតគោ ដោយយល់ថា ការធ្វើត្រាប់តាមសត្វទាំងនោះ ពួកគេនឹងបានសុខ ។ ការប្រព្រឹត្តបែបនេះ ព្រះពុទ្ធបានសំដែងថា ជាការប្រព្រឹត្តគ្មានបានផលអ្វីឡើយ ។ ថ្នាក់សោតាបានលះបង់នូវការប្រព្រឹត្តបែបនេះ ដើម្បីលោកប្រតិបត្តិត្រឹមត្រូវតាមសីលសមាធិបញ្ញាហើយក៏ដោយ ក៏លោកចាត់ទុកការប្រតិបត្តិនេះ គ្រាន់តែជាមធ្យោបាយចេញចាកទុក្ខប៉ុណ្ណោះ ពុំមែនជាកម្មវត្ថុនៃការប្រកាន់ឡើយ ។ អរិយបុគ្គលទី១ថ្នាក់សោតាបន្នបុគ្គលនេះនឹងរួចចាកទុក្ខ ផុតកើតចាស់ឈឺស្លាប់ យ៉ាងយូរបំផុតត្រឹមតែ៧ជាតិ ។ ដូច្នេះសម្បត្តិសោតានេះជាសម្បត្តិដ៏ខ្ពង់ខ្ពស់លើសសម្បត្តិនានាក្នុងលោក ។

ចំពោះប្រទេសឯករាជ្យវិញ គ្រាន់តែជាអំណាចគ្រប់គ្រងខ្លួនដោយខ្លួនឯង គ្មានបរទេសត្រួតត្រាពីលើប៉ុណ្ណោះ ពុំមែនបានសុខសន្តិភាពរហូតដោយគ្មានបញ្ហាឡើយ ព្រោះអ្វីៗស្ថិតនៅក្នុងភាពពុំទៀង ។ ការទៅកើតក្នុងឋានសួគ៌ ទោះបីសោយទិព្វសម្បត្តិទាំង១០ប្រការ ប្រសើរជាងឋានមនុស្សពិតមែន ប៉ុន្តែជាឋានស្ថិតក្រោមអំណាចត្រៃលក្ខណ៍ គឺអនិច្ចំ ទុក្ខំ និងអនត្តាដូចឋានមនុស្សដែរ ។ ចំណែកអធិបតេយ្យ គឺអំណាចក្នុងលោក គឺអំណាចត្រួតត្រាលើសង្គមតូច សង្គមធំ រហូតដល់សហគមន៍ពិភពលោក ក៏មិនប្រសើរជាងអរិយបុគ្គលថ្នាក់សោតាបន្នបុគ្គលឡើយ ព្រោះអំណាចទាំងនោះពុំអាចកំចាត់ការកើតចាស់ឈឺស្លាប់បានឡើយ ។៚

✧ ✧

✧

ប្រ

☆ ☆

☆